01206335

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 23 / 02 / 2016
ម៉ោង (Time/Heure) : 15:55
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E315/1/5

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៦

**ជូនចំពោះ÷** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី÷** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន÷** **លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ÷** **សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខ សុំឲ្យទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយទាក់ទងនឹងការប្រព្រឹត្តិចំពោះជនជាតិចាម អនុលោមតាមវិធាន ៨៧(៤)**

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើរបស់សហមេធាវីនាំមុខ សុំឲ្យទទួលយកជាភ័ស្តុតាងអនុលោមតាមវិធាន៨៧(៤) នូវឯកសារ E319/13.3.41 ដែលជាកំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1013 ពីការិយាល័យសហចៅក្រមស៊ើបអង្កេត "សំណើ" (ឯកសារ E315/1/4)។ សំណើនេះ ដាក់នៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៦ គឺបានធ្វើឡើងរួមគ្នាជាមួយនឹងសំណើរបស់សហមេធាវីនាំមុខ សុំដាក់បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវផ្តល់សក្ខីកម្មនៅក្នុងសវនាការលើសេចក្តីថ្លែងទុក្ខសោកវេទនា និងព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង នាពេលខាងមុខទាក់ទងនឹងផ្នែកជំនុំជម្រះលើការប្រព្រឹត្តិទៅលើក្រុមគោលដៅជាក់លាក់ រួមមានការប្រព្រឹត្តិទៅលើជនជាតិចាម។

២. អង្គជំនុំជម្រះកត់សម្គាល់ថា ឯកសារ E319/13.3.41 ក៏ធ្លាប់ជាកម្មវត្ថុនៃសំណើមួយទៀត ដែលសុំឲ្យទទួលយកជាភ័ស្តុតាងនូវកំណត់ហេតុនៃការស្តាប់ចម្លើយចំនួន ២៥ អនុលោមតាមវិធានផ្ទៃក្នុង ៨៧(៣) និង ៨៧(៤) ដែលបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ នៅថ្ងៃទី

២៥ ខែ កញ្ញា ឆ្នាំ ២០១៥ (ឯកសារ E319/32)។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចទទួលយកសំណើនេះ នៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦ ( E319/32/1)។ ដូច្នេះហើយទើបមានការដាក់លេខ E3/9650 ដើម្បីសម្គាល់ឯកសារ E319/13.3.41 (សូមមើលលេខរៀងទី ៩ នៅក្នុងឧបសម្ព័ន្ធ ក ឯកសារ E319/32/1.1)។

៣. ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា សំណើសុំរបស់សហមេធាវីនាំមុខ លែងមានភាពចាំបាច់ទៀតហើយ។

៤. នេះគឺជាការឆ្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងសំណើ E315/1/4។